# ព្រះវិហារចាស់ក្នុងវត្តវារិន្ទនិងគំនូរបុរាណ

វត្តវារិន្ទ ឬវត្តព្រែកលៀប កសាងនៅប្របដងទន្លេមេគង្គ ក្នុងសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ បច្ចុប្បន្នវត្តនេះមានព្រះវិហារពីរ ពោលគឺព្រះវិហារចាស់ស្ថិតនៅផ្នែកខាងកើតធ្លាវត្ត ខិតទៅក្បែរមាត់ទន្លេ។ បើផ្អែកតាមផ្ទាំងចារឹកតូចមួយចារជាប់លើជញ្ជាំង គេដឹងថាការកសាងព្រះវិហារនេះចាប់ផ្តើមតាំងពីពុទ្ធសករាជ២៤៥០ ត្រូវនឹងឆ្នាំ១៩០៧។ ប៉ុន្តែដោយកត្តាអាយុកាលនិងឆ្លងកាត់សង្គ្រាមផង ព្រះវិហារខាងលើបានពុកផុយ ខូចខាតដោយអន្ទើ ហើយក្រោយមកព្រះសង្ឃ អាចារ្យ គណៈកម្មការវត្ត និងពុទ្ធបរិស័ទជិតឆ្ងាយ បានរួមសាមគ្គីជួសជុលថែទាំជាបន្តបន្ទាប់។ លុះដល់ឆ្នាំ២០១៧ ព្រះវិហារនេះបានជួសជុលម្តងទៀតលើផ្នែកគ្រឿងបង្គុំខាងលើ រចនាសម្ព័ន្ធខាងក្រោម និងការលម្អលើជញ្ជាំង ទ្វារ បង្អួច និងគូរគំនូរថ្មីជាដើម (រូបលេខ១)។



រូបលេខ១ ព្រះវិហារពេលកំពុងរៀបចំជួសជុល
(រូបថត៖ SPACE BOX)



រូបលេខ២ ព្រះវិហារក្រោយជួសជុលរួចជាស្ថាពរ
(ថតឆ្នាំ២០២២ )

ព្រះវិហារចាស់វត្តវារិន្ទ គឺជាសំណង់បុរាណតូចច្រឡឹង ប្រភេទព្រះវិហារជហ្វាបួន[១] កសាងឡើងដោយមានជញ្ជាំង និងសសរជុំវិញរៀបឥដ្ឋបូកបាយអ ដំបូលប្រក់ក្បឿងស្រកាលេញ និងសសរខាងក្នុងសាងអំពីឈើ។ លើជញ្ជាំងខាងកើតមានចារឹកមួយចារសេចក្តី១៥បន្ទាត់ថា "(១)សុភមសតុ ព្រ:ពុទ្ធសករាជព្រ:សាស្នាកាលក (២)នូវទៅបាន ២៤៥០ព្រ:វស្សា បច្ចុបន្នឆ្នាំមមែ សប្ត (៣)សក ព្រ:មង្គលថេរ អុក និងអ្នកឧកញ៉ាមហែយ

[១] សូមអានបន្ថែម "សំណង់នៅតាមវត្ត" ដោយ ព្រាប ចាន់ម៉ារ៉ា ២០១៧: ១៣-២៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*គោ (៤)គាសែនា ចុងប៉ា អ្នកកែវ និងបុត្រប្រុះស្រីឈ្មោះគាន (៥)ឈីវហ៊ា [គានឈីវ]ហេង, នាងអេង ញាវ, នាងអេង លង, គានឈីវ គ្រុយ ,[គានឈីវ]ចាវ, [គានឈីវ]ស៊ុន, (៦)បាន សាងព្រះវិហារវត្តវ៉ារិន្ទព្រែកលាពនេះ ហើយសាង (៧)ព្រះជ័យ១អង្គ ព្រះស្ពាន់១អង្គ ព្រះមារ ១អង្គ និងព្រះត្រៃបិដក១ (៨)គម្ពី ដងទុង២ សាលា១ សាងដាខ្សែព្រះគម្ពីប្រគេនដល់ព្រះ (៩)ភិក្ខុសយ់ដម្កលទុកក្នុងព្រះពុទ្ធសាស្នាឱ្យគ្រុព៥០០០ព្រះវ (១០)ស្សា លុះដលព្រះពុទ សាស្នា២៤៥៣ព្រះវស្សា បច្ចុបន (១១)ផ្តាំច ទោសក្ស ធ្វើបុណបនចុះសីម៉ា[...]ដាឆ្លងដា (១២)កទានមានមារប្រោកនៅអ្សអ្នកប្រដា ខ្ញុំមសូមប្រថ្នាអណា (១៣)គុតជាតិទៅឯមុគ សូមកំចាត់នៅអកុសលកំមទ្វាំបុន្នានហើ្យ (១៤)យឱ្យបានសំរេចមគនិងផលសូមទាន់ព្រះ សីអាមេតេយ (១៥)បរមពោធីសត្តសូមសំរេចផលនីពានបច្ចយោហោង”[២]*



***រូបលេខ៣ ផ្ទាំងចារឹកដើមនៃព្រះវិហារវត្តវារិន្ទ***

តាមរយៈខ្លឹមសារនៃផ្ទាំងចារឹកខាងលើ គេអាចដឹងថា ព្រះវិហារវត្តវារិន្ទចាប់ផ្តើមកសាងនៅក្នុងឆ្នាំ១៩០៧ (ព.ស. ២៤៥០) រួចរាល់ស្ថាពរធ្វើបុណ្យបញ្ចុះសីមាឆ្លងក្នុងឆ្នាំ១៩១០ (ព.ស.២៤៥៣) ហើយបើគិតមកដល់សព្វថ្ងៃមានអាយុកាលជាង១សតវត្សរ៍ៗ មិនតែប៉ុណ្ណោះ គេដឹងថា ការកសាងព្រះវិហារនេះ ដោយសទ្ធាដឹកនាំរបស់ព្រះមង្គលថេរនាម “អុក” អ្នកឧកញ៉ាមហៃយ(មហា?) ភោគា ចុងប៉ា និងភរិយា ព្រមទាំងបុត្រាបុត្រី និងញាតិសន្តានៗ ទន្ទឹមនឹងនោះ ម្ចាស់ទានបានសាងព្រះជ័រ១ ព្រះស្ពាន់១

---

[២] ខ្ញុំសូមអធ្យាស្រ័យចំពោះការចម្លងពាក្យពេចន៍ក្នុងចារឹកខាងលើ ដែលអាចខ្វះចន្លោះដោយអចេតនាៗ ប៉ុន្តែក្រោយជួសជុលព្រះវិហាររួច ខ្លឹមសារនៃផ្ទាំងចារឹកនេះបានចម្លងជាថ្មី ដោយប្រើតាមពាក្យសម័យបច្ចុប្បន្នៗ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ព្រះមាស១ ដងទង់១គូ ព្រមទាំងសាងគម្ពីរតម្កល់ក្នុងព្រះសាសនាប្រាថ្នាឱ្យបានគ្រប់ ៥០០០ព្រះវស្សា និងសូមបានទាន់ព្រះសិអារ្យមេត្រីបរមពោធិសត្វ (រូបលេខ២៣)។

ចាប់ពីឆ្នាំ២០១៧ ព្រះវិហារបុរាណវត្តវាំរិន្ទបានរៀបចំជួសជុលម្តងទៀត ដោយកែលម្អផ្ទាខាងក្រៅ និងខឿន ព្រមទាំងពង្រឹងសសរជុំវិញ ជាពិសេសជួសជុលប្តូរគ្រឿងបង្គុំឈើផ្នែកខាងលើ និងប្តូរក្បឿងថ្មីទាំងស្រុង។ ការជួសជុលនេះគេមើលឃើញថា បានរក្សាលំនាំដើមនៃសំណង់ និងបំពេញបន្ថែមនូវចំណុចប្រឈមការខូចខាតនានា (រូបលេខ២៤)។ ព្រះវិហារកសាងឡើងនៅលើខឿនកម្ពស់ប្រហែលជាងកន្លះម៉ែត្រ មានជណ្តើរឡើងនៅទិសខាងកើត២ ទិសខាងលិច២ ព្រមទាំងសាងឱ្យមានសសរបាំងសាចរាងបួនជ្រុងធំៗព័ទ្ធជុំវិញ។ ចំពោះដំបូល គេសង់ជារបៀបព្រះវិហារជហ្វាបួន មានស្ថាបដំបូល២ជាន់ និងមានហប់ខ្យល់ផង។ ប៉ុន្តែយ៉ាងណាក្តី ទម្រង់ទូទៅនៃព្រះវិហារវត្តនេះហាក់ដូចជាមានលក្ខណៈស្រដៀងនឹងព្រះវិហារវត្តចិនដំដែកដែលកសាងឆ្នាំ១៨៨៧-១៨៩០។[៣]



រូបលេខ២៤ សកម្មភាពជួសជុលព្រះវិហារវត្តវាំរិន្ទ (រូបថត៖ ព្រីង ឆាង)

[៣] សូមអាន "សិល្បៈនិងស្ថាបត្យកម្មនៃវិហារបុរាណវត្តចិនដំដែក" ដោយ ហៀន សុវណ្ណមរកត ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/13632 (ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែក ចំពោះហោជាងទាំងពីរនៃព្រះវិហារវត្តវាំងនិ គេធ្វាក់រចនាអំពីស៊ីម៉ងត៍ ជាក្បាច់ភ្ញីទេសយ៉ាងរស់រវើកនៅលើផ្ទៃពណ៌សដូចគ្នាទាំងពីរផ្ទាំង។ ប៉ុន្តែនៅកណ្ដាលផ្ទៃហោជាងនីមួយៗ គេធ្វាក់ជារង្វង់កង់ពុទ្ធចក្រតម្កល់លើជើងពាន មានពន្លឺរង្សីនៅខាងលើ និងមានចារឹកខ្លីមួយបន្ទាត់នៅខាងក្រោម។ ចារឹកលើហោជាងខាងកើតមានអក្សរ៥តួគឺ "រតនតយ" ដែលអ្នកខ្លះយល់ថាសំដៅលើការបង្ហាញការគោរពដល់ "រតនត្រ័យ" ក្នុងព្រះពុទ្ធសាសនាគឺ "ពុទ្ធរតន" "ធម្មរតន" និង "សង្ឃរតន" (រូបលេខ២៥)។ ចំណែកឯចារឹកនៅលើហោជាងខាងលិចគឺ "ព.ស.២៤៩០" ដែលសំដៅដល់កាលបរិច្ឆេទនៃការចាប់ផ្ដើមសាងសង់ព្រះវិហារនេះ ដូចខ្លឹមសារមានចារលើផ្ទាំងចារឹកតូចមួយដូចបានរៀបរាប់មកខាងលើ (រូបលេខ២៦)។




រូបលេខ២៥ ហោជាងខាងកើត




រូបលេខ២៦ ហោជាងខាងលិច

នៅផ្នែកខាងក្នុងព្រះវិហារ គេសាងឡើងដោយមានល្វែងគ្រឹះនៅកណ្ដាល អមដោយរបៀងសងខាង ហើយនៅត្រង់ចុងល្វែងគ្រឹះផ្នែកខាងលិច គឺជាបល្ល័ង្កព្រះដ៏ធំ។ ទន្ទឹមនឹងនេះ នៅអមសងខាងល្វែងគ្រឹះគឺមានសសរឈើមូលពីរជួរតម្កល់លើជើងសសររាងដូចថូ ដូចសសរខាងក្នុងព្រះវិហារវត្តចិនដំដែក។ នៅលើសសរនីមួយៗ គេរចនាជារូបនាគព័ទ្ធពេនចុះមក ហើយសសរខ្លះមានចារអក្សរចិនផងដែរ។ នៅផ្នែកខាងលើ គឺជាគ្រឿងបង្គុំឈើ និងពិតានឈើក្រាលពេញលើល្វែងគ្រឹះ។ បន្ទាប់ពីជួសជុលរួច នៅលើផ្ទៃពិតាននេះគេគូរលម្អដោយរូបទេពនិករផ្សេងៗកាន់ផ្កា ឬផ្ចិតហោះហើរលើអាកាស។ ប៉ុន្តែនៅត្រង់ចំពីលើបល្ល័ង្កព្រះដ៏រ គេគូរជារង្វង់ពន្លឺធពណ្ណរង្សី (រូបលេខ២៧-៨)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត





រូបលេខ៧-៨ ផ្នែកខាងក្នុងព្រះវិហារចាស់វត្តវារិន្ទ

គំនូរខាងក្នុងព្រះវិហារ គេឃើញមានពីរផ្នែកគឺ គំនូរនៅត្រង់ហប់ខ្យល់ និងគំនូរថ្មីលើជញ្ជាំង។ ចំពោះគំនូរលើហប់ខ្យល់ គឺជាប្រភេទគំនូរបុរាណដែលគូរលើបន្ទះក្តារទំហំទទឹងប្រហែល៤តឹក លើកយកអន្ទើក្នុងពុទ្ធប្រវត្តិ និងក្នុងជាតក។ ក្នុងផ្ទាំងគំនូរខ្លះ មានសេចក្តីអធិប្បាយវែងឆ្ងាយអំពីសាច់រឿងនោះ តែគំនូរខ្លះគេឃើញមានតែចំណងជើងប៉ុណ្ណោះ។ នៅហប់ខ្យល់លើព្រះដីរ៍ គេគូរព្រះមោគ្គលានគង់កណ្តាលពពួកទេវតា (រូបលេខ៩)។ រីឯនៅលើហប់ខ្យល់ខាងកើត ឈមនឹងព្រះដីរ៍គេគូរបង្ហាញត្រង់ព្រះអង្គផ្ចាញ់មារ។ នៅលើហប់ខ្យល់ខាងត្បូង (រាប់ពីកើតទៅលិច) គេគូរសាច់រឿងដូចជានេមិរាជ, សុវណ្ណសាម, ព្រះជនក (រូបលេខ១០), មហោសថ(?) និងព្រះតេមិយ។ នៅលើហប់ខ្យល់ខាងជើង (រាប់ពីលិចទៅកើត) គេគូរសាច់រឿងដូចជា ព្រះភូរិទត្ត, ចន្ទកុមារ(រូបលេខ១១), នារទព្រហ្ម (រូបលេខ១២), វិធូរបណ្ឌិត និងព្រះវេស្សន្តរ។



រូបលេខ៩ គំនូរព្រះមោគ្គលានលើហប់ខ្យល់



រូបលេខ១០ គំនូរព្រះជនកលើហប់ខ្យល់ខាងត្បូង

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១១ គំនូររឿងចន្ទកុមារ



រូបលេខ១២ គំនូររឿងព្រះនារទព្រហ្ម

ចំពោះគំនូរលើជញ្ជាំងផ្នែកខាងក្នុងព្រះវិហារវត្តវារិន្ទ គឺជាគំនូរថ្មីទើបនឹងគូរពេលជួសជុលព្រះវិហារ ដ្បិតដើមឡើយនៅលើជញ្ជាំងព្រះវិហារនេះពុំមានគំនូរជាសាច់រឿងវែងឆ្ងាយទេ ពោលគឺមានតែផ្ទាំងគំនូរគូរលើក្រណាត់ភ្ជាប់នឹងស៊ុមឈើដាក់ព្យួរលើបង្អួចតែប៉ុណ្ណោះ។ សាច់រឿងគំនូរថ្មីលើជញ្ជាំងមានចំនួន២២ផ្ទាំង ដែលគេគូររឿងពុទ្ធប្រវត្តិនិងព្រះវេស្សន្តរ (១ផ្ទាំង) ជាលំនាំគំនូរបុរាណ។[៨] អ្វីដែលគួរឱ្យចាប់អារម្មណ៍ គឺវិចិត្រករផ្ដើមខ្សែរឿងលើជញ្ជាំងខាងត្បូង ដោយលើកយកកណ្ឌឆក្សត្រ(?) នៃរឿងវេស្សន្តរមកបង្ហាញ (រូបលេខ១៣)។ សាច់រឿងបន្ទាប់ពីនោះមកមានដូចជា ទ្រង់ប្រសូត(រូបលេខ១៤), ទតសួន, យាងចេញបួស, កាត់ព្រះកេសា, ធ្វើទុក្ខកិរិយា និងនាងសុជាតាថ្វាយចង្ហាន់។ ជញ្ជាំងខាងលិចមានសាច់រឿងដូចជា ព្រះអង្គគង់លើស្បូវភ្លាំង, ផ្ចាញ់មារ (ចំខាងក្រោយបល្ល័ង្កព្រះដីរ៍)និងប្រោសបញ្ចវគ្គីយ៍។ ជញ្ជាំងខាងជើងមានសាច់រឿងដូចជា ប្រោសយសកុលបុត្រ, ប្រោសព្រះបាទពិម្ពិសារ, ប្រោសពុទ្ធបិតា, ប្រោសញាតិវង្ស, ធ្វើចតុរង្គមហា

[៨] តួអង្គសំខាន់ៗក្នុងគំនូរបែបនេះភាគច្រើនប្រើពុម្ពសម្រាប់ព្រាង រួចហើយទើបគេកាត់សសៃរនិងផាត់ពណ៌។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

សន្និបាត, ប្រោសពុទ្ធមាតានៅឋានត្រៃត្រឹង្ស, មារនិមន្តព្រះអង្គចូលបរិនិព្វាន, និងព្រះអង្គទ្រង់ដាក់អាយុសង្ខារ។ ចំណែកឯលើជញ្ជាំងខាងកើតគឺមានសាច់រឿង៣ផ្ទាំងបន្តរឿងជញ្ជាំងខាងជើងគឺ "ព្រះអង្គទ្រង់ប្រឈួន" គូរខាងឆ្វេង "ទ្រង់បរិនិព្វាន" គូរកណ្ដាល (រូបលេខ១៩) និង "ថ្វាយព្រះភ្លើងព្រះបរមសពព្រះសម្មាសម្ពុទ្ធ" គូរខាងស្តាំ។[៩] រីឯនៅតាមផ្ទៃជញ្ជាំងត្រង់ចន្លោះទ្វារនិងបង្អួច គេគូរព្រះកាយវិការផ្សេងៗរបស់ព្រះពុទ្ធដូចជាសមាធិ, ទ្រង់បាត្រ, និងគូរព្រះអគ្គសាវ័កគង់ប្រចាំទិសតូចធំនានាដូចជា ព្រះសារីបុត្រ (ទក្សិណ), ឧបាលិ (និរតី), ព្រះអានន្ទ (បស្ចិម), មោគ្គល្លាន (ឧត្តរ), ព្រះគវម្បតិ ឬព្រះខ្វាមក់ (ពាយ័ព្យ), រាហុល (ឦសាន), និងកោណ្ឌញ្ញ (បូព៌)។



រូបលេខ១៣ គំនូររឿងព្រះវេស្សន្តរ (ឆក្សត្រ?)



រូបលេខ១៨ ទ្រង់ប្រសូត



រូបលេខ១៩ ទ្រង់បរិនិព្វាន

សង្ខេបសេចក្ដីមក ព្រះវិហារវត្តវារិន្ទ ឬវត្តព្រែកលៀប គឺជាព្រះវិហារបុរាណមួយដែលមានលក្ខណៈដើមមួយភាគស្រដៀងព្រះវិហារវត្តចិនដំដែក។ សាច់រឿងគំនូរបុរាណលើហប់ខ្យល់ភាគច្រើនជារឿងក្នុងជាតក ដែលជាទីនិយមក្នុងគំនូរតាមវត្ត។ ចំណែកឯគំនូរថ្មីដែលគូរលើជញ្ជាំងជុំវិញមានលំនាំជាគំនូរបុរាណមួយបែប ដែលគេតែងនិយមឃើញគូរសព្វថ្ងៃ៕

[៩] សូមអានបន្ថែម៖ សាន ផល្លា ២០០៧

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ព្រាប ចាន់ម៉ារ៉ា

២០១៧. *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

សាន ផល្លា

២០០៧, *គំនូរនៅតាមវត្ត*, រៃឃំ, ភ្នំពេញ

ហៀន សុវណ្ណមរកត

២០២១, "សិល្បៈនិងស្ថាបត្យកម្មនៃវិហារបុរាណវត្តចិនដំដែក" ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/13632 (ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត